នស/រកម/១២១៥/០១៦

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋសភា
ចូល លេខ ០៥០ ផស
ថ្ងៃទី ១១/០១ ឆ្នាំ២០១៦ ម៉ោង ១៥:២០
បញ្ជូនទៅ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • ROYAL • LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង

# ឆ្នាំ ២០១៦

# ជំពូកទី ១
## ថវិកាថ្នាក់ជាតិ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ឲ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ នូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគ និងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ក១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ១៧ ៦១២ ៤៧៧ លាន រៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត......................................................១៣ ៤០៧ ២៦៣ លាន រៀល
- ចំណូលមូលធន....................................................៤ ២០៥ ២១៤ លាន រៀល
  - \+ ចំណូលមូលធនក្នុងប្រទេស..................................១៣០ ៨៦៤ លាន រៀល
  - \+ ចំណូលមូលធនក្រៅប្រទេស.............................៤ ០៧៤ ៣៥០ លាន រៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ..........................................................២០៣ ០០០ លាន រៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ......................................................៣ ៨៧១ ៣៥០ លាន រៀល ។

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានកំណត់ស្មើនឹង ១៧ ៤៦២ ៤៧៧ លាន រៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត.....................................................១១ ១៥៦ ៩៨៩ លាន រៀល
- ចំណាយមូលធន...................................................៦ ៣០៥ ៤៨៨ លាន រៀល

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

..............................................................១ ៩២៥ ០០០ លាន រៀល

- ដោយថវិកាថ្នាក់ជាតិ..............................១ ៦៧៥ ០០០ លាន រៀល
  - គម្រោងវិនិយោគផ្ទាល់...............១ ២២៤ ០០០ លាន រៀល
  - បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស ..............................................៤៥១ ០០០ លាន រៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ

........................................................២៥០ ០០០ លាន រៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

........................................................៣ ៨៧១ ៣៥០ លាន រៀល

គ- ការទូទាត់ការខ្ចី............................................... ៥០៩ ១៣៨ លាន រៀល ។

## មាត្រា ៣.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានកំណត់ស្មើនឹង ១១ ១៥៦ ៩៨៩ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

## មាត្រា ៤.-

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨ ត្រូវបានកំណត់ស្មើនឹង ១៦ ៨៤២ ១៨២ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគម្រោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

## មាត្រា ៥.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយ មូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា.................................៦ ៣០៥ ៤៨៨ លាន រៀល
- ឥណទានទូទាត់....................................... ៦ ៣០៥ ៤៨៨ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា................................ ១ ៩២៥ ០០០ លាន រៀល
- ឥណទានទូទាត់....................................... ១ ៩២៥ ០០០ លាន រៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា.................................៣ ៨៧១ ៣៥០ លាន រៀល

- ឥណទានទូទាត់..................................៣ ៨៧១ ៣៥០ លាន រៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា................................ ៥០៩ ១៣៨ លាន រៀល
- ឥណទានទូទាត់...................................... ៥០៩ ១៣៨ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដូចមានចែងក្នុងតារាង "**ឥ២**" និង "**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

## មាត្រា ៦._

គុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ដែលបានរៀបចំនៅក្នុងតារាង "**ត១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិ ត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL